ភ្នំពេញ , ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣

# អនុក្រឹត្យលេខ ០២ អនក្រ

## រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់សម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ។
- យោងអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ស្ដីការរៀបចំនិងការប្រព្រឹត្តទៅ នៃ អគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា ។

## សំរេច

**ប្រការ ១ :** នាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា និង ក្រុមហ៊ុនអាកាសចរកម្ពុជា ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ២ :** រចនាសម្ព័ន្ធ តួនាទី និង ភារកិច្ចរបស់នាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជានិងក្រុមហ៊ុន អាកាសចរកម្ពុជា ត្រូវកំណត់ឡើងវិញអោយបានសមស្រប ។

**ប្រការ ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ប្រធាននាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជានិងក្រុមហ៊ុនអាកាសចរកម្ពុជាត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិង ចុះហត្ថលេខានេះតទៅ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា

ព្រះហស្ថលេខា ហត្ថលេខា

ស្ដេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

****

www.pheakdeylaw.com